**ចំណាប់អារម្មណ៍របស់**

**លោកស្រី ជឹម ម៉ាណាវ នាយិកាប្រតិបត្តិ អង្គការវិទ្យាស្ថានបើកទូលាយ**

**ក្នុងកិច្ចប្រជុំពិភាក្សាពីកម្រងសំណួរនៃការស្រាវជ្រាវអំពើហិង្សាលើយេនឌ័រ**

**ភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១២**

---------

សូមគោរព លោក គង់ឆេង ប្រធានសមាគមក្រុមប្រឹក្សាឃុំ/សង្កាត់ខេត្តកណ្តាលនិងជាប្រធានគណៈកម្មាធិការទំនាក់ទំនងសាធារណៈនៃសម្ព័ន្ធភាពជាតិ ឃុំ/សង្កាត់

សូមគោរព លោកស្រី អស់លោកដែលមានវត្តមាននាពេលនេះ

ថ្ងៃនេះអង្គការវិទ្យាស្ថានបើកទូលាយមានកិត្តិយស និងមានសេចក្តីសោមនស្សរីករាយដោយបានទទួលលោកជំទាវ អស់លោក លោកស្រីក្នុងកិច្ចប្រជុំនេះ។ តាងនាមអ្នករៀបចំកម្មវិធី នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅចំពោះលោកជំទាវ លោកស្រី អស់លោក ដែលបានឆ្លៀតពេលមមាញឹកអញ្ជើញមកចូលរួមក្នុងកិច្ចប្រជុំពិភាក្សាពីកម្រងសំណួរនៃការស្រាវជ្រាវអំពើហិង្សាលើយេនឌ័រថ្ងៃនេះ។ ការប្រជុំនេះត្រូវបាន សហការរៀបចំដោយសម្ព័ន្ធ ភាពជាតិឃុំ សង្កាត់ និងអង្គការវិទ្យាស្ថានបើកទូលាយ។

*គោលបំណងកិច្ចប្រជុំ៖*

- ពិភាក្សាអំពីកម្រងសំណួរនៃការសិក្សាស្រាវជ្រាវអំពីអំពើហិង្សាលើយេនឌ័រ
- ទទួលមតិយោបល់លើ កម្រងសំណួរ

លោកជំទាវ លោកស្រីអស់លោក ជាទីគោរព

អំពើហិង្សាលើស្ត្រីមានច្រើនប្រភេទ រួមមានអំពើហិង្សាលើរូបរាងកាយ លើផ្លូវចិត្ត ផ្លូវសេដ្ឋកិច្ច ។ល។ កាលពីឆ្នាំ ១៩៩៣ មហាសន្និបាតអង្គការសហប្រជាជាតិ បានដាក់

ចេញនូវនិយមន័យនៃពាក្យអំពើហិង្សាលើស្ត្រី។ នៅក្នុងសេចក្តីថ្លែងការណ៍ស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី ដែលត្រូវបានមហាសន្និបាតអនុមតិ (General Assembly resolution 48/104 of 20 December 1993 [២]) ហើយត្រូវបានគេប្រើប្រាស់ទូលំទូលាយនោះ មាត្រាមួយបានចែងថា" អំពើហិង្សាលើស្ត្រី" មានន័យថា អំពើហិង្សាទាក់ទងយេនឌ័រទាំងឡាយណា ដែលនឹងនាំឲ្យមានគ្រោះអន្តរាយ ឬការឈឺចាប់ផ្លូវរាងកាយ ផ្លូវភេទ ឬផ្លូវចិត្ត ដោយរួមមានការគំរាមកំហែង បង្ខិតបង្ខំ ឬរំលោភបំពាន សេរីភាព ដែលអំពើទាំងនោះកើតឡើងនៅទីសាធារណៈ ឬជីវិតឯកជន។

តាមតួលេខទទួលបាន អំពើហិង្សាលើស្ត្រីមានការរីករាលដាលគួរឲ្យភ្ញាក់ផ្អើល។ គេប៉ាន់ប្រមាណជាទូទៅថា ក្នុងចំណោមស្ត្រី ៣នាក់នៅទូទាំងពិភពលោក មានម្នាក់នឹងត្រូវទទួលរងនូវការឈឺចាប់ដោយ អំពើហិង្សាទាក់ទងយេនឌ័រ នៅក្នុងជីវិតរស់នៅរបស់ពួកគេ។ អំពើទាំងនោះ រួមមានការវាយដំ រំលោភ ការវាយប្រហារ ការត្រូវគេជួញដូរ ត្រូវគេសម្លាប់ ការប្រមាថ ការដាក់កំហិតក្នុងការដើរហើរ និងទំនាក់ទំនង សង្គម។ល។ (UN Commission on the status of women 28/2/00)[៣]

អំពើហិង្សាលើស្ត្រី ត្រូវបានគេរកឃើញថាជាឧបសគ្គចម្បងមួយក្នុងការអភិវឌ្ឍ ដោយសារថាអំពើហិង្សាលើរាងកាយក្តី ផ្លូវចិត្តក្តី សុទ្ធសិងបានធ្វើឲ្យការចូលរួមរបស់ស្ត្រីមានកម្រិត ក្នុងការចូលរួមយ៉ាងពេញលេញក្នុងសេដ្ឋកិច្ច សង្គមនិងនយោបាយ។ អំពើហិង្សាលើស្ត្រីបានធ្វើឲ្យអន្តរាយដល់សមភាពយេនឌ័រ។ អំពើហិង្សាលើស្ត្រី គឺជាលទ្ធផលដែលអាចមើលឃើញច្បាស់អំពីអសមភាពយេនឌ័រ និងការខ្វះអំណាចរបស់ស្ត្រី។ ដូច្នេះហើយ យើងមិនអាចសម្រេចបានគោលដៅអភិវឌ្ឍសហស្សវត្សឡើយ ប្រសិនបើអំពើរំលោភបំពាននេះនៅតែកើតមាន (Ending Violence against Women and Girls-Protecting Human Rights, GTZ)។

តែយើងមិនទាន់មានតួលេខរួមមួយអំពីអំពើហិង្សាលើយេនឌ័រឡើយ។ យើងទទួលបានតួលេខខុសៗគ្នាពីស្ថាប័នផ្សេងៗ។ អង្គការវិទ្យាស្ថានបើកទូលាយ សហការជាមួយសម្ពន្ធភាពជាតិឃុំសង្កាត់ រៀបចំឲ្យមានការសិក្សាស្រាវជ្រាវមួយអំពី អំពើហិង្សាលើយេនឌ័រ។ ការសិក្សាស្រាវជ្រាវ ត្រូវបានធ្វើឡើងក្នុងគោលបំណងរកឲ្យឃើញនិងផ្តល់ដល់

---

២. http://www.unhchr.ch/huridocda/huridoca.nsf/(Symbol)/A.RES.48.104.En

៣. http://www.peacewomen.org/un/ecosoc/CSW/CSWindex.html

ស្ថាប័នពាក់ព័ន្ធនូវតួលេខរួមមួយនិងសូចនាករនានាប្រយោជន៍ដើម្បីជាអនុសាសន៍ដល់ស្ថាប័នទាំងនោះក្នុងការធ្វើគោលនយោបាយជំរុញសមភាពយេនឌ័រនៅប្រទេសកម្ពុជា។ ដើម្បីចាប់ផ្តើមនូវ ការសិក្សាស្រាវជ្រាវនេះ សម្ពន្ធភាពជាតិឃុំសង្កាត់ បានសហការជាមួយអង្គការវិទ្យាស្ថានបើកទូលាយ ចងក្រងនូវកម្រងសំណួរដែលមានសេចក្តីព្រាងដាក់ជូនអស់លោក លោកស្រី ពិនិត្យ និងផ្តល់មតិយោបល់ ដើម្បី ធ្វើឲ្យ កម្រងសំណួរនេះ មានលក្ខណៈគ្រប់ជ្រុងជ្រោយនិងសុក្រឹត។ ដូច្នេះការចូលរួមផ្តល់មតិយោបល់ របស់អស់លោកលោកស្រីពិតជាមានសារសំខាន់ណាស់សម្រាប់ការសិក្សាស្រាវជ្រាវនេះ។ សូមអស់លោកលោកស្រីចូលរួមឲ្យបានផុលផុស។

មុននិងបញ្ចប់ នាងខ្ញុំសូមជូនពរ លោកជំទាវ អស់លោក លោកស្រីដែលមានវត្តមាននាពេលនេះ សូមប្រកបដោយសុខភាពបរិបូរណ៍ បញ្ញាវាងវៃ និងទទួលបានជោគជ័យក្នុងរាល់ការងារ។

សូមអរគុណ